| | | |
|---|---|---|
| ករណី | : | ចាប់ផ្សឹកយកទៅបាត់ |
| លេខករណី | : | TKO ១០-០៧-០៧ |
| ថ្ងៃខែឆ្នាំកើតហេតុ | : | ថ្ងៃទី ៣០ ខែ ៦ ឆ្នាំ ២០០៧ វេលាម៉ោង ៣:៤០ នាទីល្ងាច |
| កន្លែងកើតហេតុ | : | នៅវត្តសីហារតនារាម វត្តព្រះមេគណខេត្តតាកែវ |
| ជនរងគ្រោះ | : | ព្រះចៅអធិការព្រះនាម ឥន្ទបញ្ញា (INDA PAÑÑĀ )ទីម សាខន ជាខ្មែរកម្ពុជាក្រោមកើត នៅភូមិខ្លាគ្រហឹម ( បាជុក) ឃុំបាជុក ស្រុកស្វាយទង ( ទ្រីតូង) ខេត្ត មាត់ជ្រូក ( បច្ចុប្បន្នអាងយ៉ាង) កម្ពុជាក្រោម ។ |
| ជនប្រព្រឹត្តិ | : | ព្រះមហាសង្ឃរាជ ទេព វង្ស និងមន្ត្រីសង្ឃជាន់ខ្ពស់ចំនួន ០៥អង្គផ្សេងទៀត : ១-ព្រះពោធិវ៉ាំង អម ឡឹមហេង, ២-សម្តេច វ៉ន វ័តន៍, សម្តេច ណយ ច្រឹក, ព្រះអនុគណភ្នំពេញសម្តេច សៅ ច័ន្ទល និងព្រះពុទ្ធឃោសាចារ្យ ឡុង គីមឡេង។ |

## ដំណើររឿងកើតហេតុ

នៅថ្ងៃទី ៣០-៦-២០០៧ វេលាម៉ោង៣:៤០ នាទីល្ងាច ព្រះតេជគុណព្រះចៅអធិការវត្តបោក្ខណារាម ភ្នំដិនខាងជើង ព្រះនាម ឥន្ទបញ្ញា ទីម សាខន អាយុ ៤០ ឆ្នាំ ជាខ្មែរកម្ពុជាក្រោម ។ បច្ចុប្បន្នជាព្រះចៅអធិការវត្តភ្នំដិនខាងជើង ក្នុងភូមិតាឡឹង, ឃុំភ្នំដិន, ស្រុកគីរីវង់, ខេត្តតាកែវ ត្រូវបានព្រះមេគណហៅទៅវត្តសីហារតនារាម រួចចាប់ផ្សឹក ព្រមទាំងបញ្ជូនតាមរថយន្តតូយ៉ូតាកាមរី ពណ៌ខៀវយកទៅបាត់តែម្តង ។

តាមការស៊ើបអង្កេតរបស់ KKKHRO បានឃើញថា នៅថ្ងៃទី៣០-៦-២០០៧ វេលាម៉ោង ១១:៣០ នាទីព្រឹកពេលព្រះសង្ឃរងគ្រោះព្រះនាម ទីម សាខន កំពុងឆាន់ចង្ហាន់ ស្រាប់តែមានទូរស័ព្ទមកពីព្រះមេគណហៅព្រះអង្គឱ្យទៅជួបព្រះអង្គ ដោយបញ្ជាក់ថាព្រះអង្គនឹកណាស់ ។ ព្រះសង្ឃរងគ្រោះបាននិមន្តទៅដល់វត្តសីហារតនារាមតាមការហៅរបស់ព្រះមេគណ ហើយនៅវេលាម៉ោង ៣:៤០ នាទីល្ងាច ស្រាប់តែឃើញព្រះសង្ឃរងគ្រោះត្រូវគេផ្សឹករួចហើយ ដោយមានសំលៀកបំពាក់ពណ៌ខៀវដើរចេញពីកុដិមេគណ មានអមដំណើរដោយមន្ត្រីសង្ឃជាន់ខ្ពស់ ៤ អង្គមកពីភ្នំពេញ នាំចូលឡានតូយ៉ូតាកាមរីពណ៌ខៀវបើកទ្វារចាំជាស្រេច និងមានម្នាក់ស្លៀកពាក់ឯកសណ្ឋានជាអង្គរក្ស រង់ចាំរុញព្រះអង្គបញ្ចូលឡាន រួចបើកចេញតាមទ្វារវត្តខាងត្បូងចេញទៅបាត់ ។ ការចាប់ផ្សឹកនេះគឺធ្វើតាមសង្ឃប្រកាសរបស់សម្តេចទេព វង្ស ថ្ងៃទី ១៦-៦-

២០០៧ ចោទព្រះអង្គថាបានប្រព្រឹត្តិខុសវិន័យពុទ្ធសាសនា ដែលធ្វើឱ្យបែកបាក់សាមគ្គីជាតិ-អន្តរជាតិ ជាពិសេសប្រទេសទាំងពីរកម្ពុជា-វៀតណាម។

នៅថ្ងៃខែឆ្នាំដដែលនោះ វេលាម៉ោង ៤:៣០ នាទីល្ងាចស្រាប់តែមានអជ្ញាធរ-ប៉ូលិសប្រហែល និងប៉េអឹមប្រហែល ១០ នាក់ មកបើកទ្វារចូលបន្ទប់ព្រះចៅអធិការ ទឹម សាខន ដោយមិនមានដីកាឆែកឆេរឡើយ។ (បន្ទប់របស់ព្រះចៅអធិការមានបីជាន់គឺជាន់ទី១ កន្លែងទទួលភ្ញៀវ និងបន្ទប់ខាងក្នុងទៀតសំរាប់ព្រះអង្គសឹង)។ ពេលប៉ូលិសចូលដល់បន្ទប់ទីពីរស្រាប់តែឃើញ ស្ត្រីពីរនាក់គឺ ឈ្មោះ កៀង យ៉ាយ អាយុ ៦៤ ឆ្នាំ ជាបាំបាយនៅក្នុងវត្ត និងស្ត្រីម្នាក់ទៀតឈ្មោះ នី ហៅស្រីអូន អាយុប្រហែល ៣០ ឆ្នាំ នៅដេកក្នុងបន្ទប់។ ប៉ូលិសក៏ឱ្យយាយ យ៉ាយចេញមកក្រៅ ហើយទុកស្រីអូនក្នុបន្ទប់សាកសួរមួយសន្ទុះក្រោយមក ក៏ដឹកចេញទៅបាត់តែម្តង។ ចំណែកព្រះសង្ឃក្នុងវត្ត និងឧបាសក-សិកាចំណុះជើងវត្ត បាននាំគ្នាមកមើល ហើយឃើញហេតុការណ៍នោះក៏សំដែងការចំឡែកចិត្តយ៉ាងខ្លាំង ហើយទាំងឧបាសក-សិកា និងព្រះសង្ឃមានសង្ឃដិកា និងនិយាយថា រឿងនេះមិនមែនជារឿងពិតឡើយ គឺគេប្រឌិតឡើងដើម្បីចោទព្រះអង្គ ពីព្រោះកន្លងមកព្រះអង្គមិនដែលមានទាកទងស្រីណាម្នាក់ឡើយ ព្រះអង្គមានតែខិតខំកាសាងវត្តអារាមកុដិសាលាបានជាច្រើន។

តាមការស៊ើបអង្កេតៈ ស្ត្រីនោះទើបតែបានមកវត្តនេះចំនួនពីរដងប៉ុណ្ណោះ គឺលើកទីមួយមុននេះប្រហែលមួយខែ មកជួបយាយកៀង យ៉ាយនេះ ហើយបានសុំគាត់ធ្វើជាម្តាយធម៌។ ហើយលើកទីពីរគឺថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ ២០០៧ នេះ គឺមកជួបយាយយ៉ាយ ហើយបានសុំគាត់ឱ្យនាំទៅជួបព្រះចៅអធិការ ទឹម សាខន ដើម្បីឱ្យព្រះអង្គស្រោចទឹកពីព្រោះនាងមិនសូវស្រួលខ្លួន។ យាយ យ៉ាយព្រមនាំនាងមកជួបព្រះចៅអធិការ ប៉ុន្តែពេលជួបព្រះចៅអធិការ ព្រះអង្គមានសង្ឃដិកាថា ឱ្យនៅរង់ចាំព្រះអង្គទីនេះសិនហើយ ពីព្រោះព្រះអង្គជាប់រវល់និមន្តទៅវត្តសីហរតនារាម តាមការនិមន្តរបស់ព្រះមេគណខេត្តតាកែវ ព្រះនាមជាស អោម។ ក្រោយពេលព្រះចៅអធិការនិមន្តទៅផុត ស្ត្រីឈ្មោះ នី នោះក៏ចូលទៅដេកក្នុងបន្ទប់ព្រះអង្គតែម្តង ដោយប្រាប់យាយយ៉ាយថា គេចូលទៅដេកសិនហើយពីព្រោះមិនសូវស្រួលខ្លួន។ ឃើញដូច្នោះយាយយ៉ាយក៏ចូលទៅដេកខាងក្នុងដែរ ហើយបានឃើញនាងនោះយកស៊ីឌីចេញពីកន្ត្រករបស់នាងមកចាក់មើលក្នុង VCD ដែលមាននៅក្នុងបន្ទប់ស្រាប ហើយក្រោយមកយាយយ៉ាយក៏ដេកលក់ទៅ ដោយមិនបានដឹងថាទ្វារខាងក្រៅចាក់សោរ ឬអត់នោះទេ ហើយដេកលក់រហូតដល់មានការឆែកឆេរតែម្តង។

សូមបញ្ជាក់ថា មុននេះពីរបីថ្ងៃស្ត្រីឈ្មោះនី ហៅស្រីអូននេះ បានមកដល់ផ្ទះលោកតាទឹម ធៀង ជាឪពុករបស់ព្រះចៅអធិការវត្តភ្នំដិន ហើយបានសុំគាត់ធ្វើជាឪពុកធម៌ដោយនៅសំរាកផ្ទះគាត់ពីរយប់ទៀតផង។





ព្រះអគ្គមហាសង្ឃរាជាធិបតី ទេព វង្ស

ភិក្ខុ ទិម សាខន

លោកតាទឹម ព្រៀងគាត់មិនព្រមទទួលទាងធ្វើជាកូនធម៌ឡើយ ពីព្រោះគាត់ ជាអ្នកបូរាណមិនចូលចិត្តស្រីតែងខ្លួនបែបស៊ុំស៊ីយ៉ាងនេះ ហើយកូនចៅរបស់គាត់ ក៏មិនព្រមដែរ ។

ការសន្និដ្ឋាន

-ការចាប់ព្រះសង្ឃទឹម សាខន មានលក្ខណៈនយោបាយច្រើនជាង និងមិនត្រឹមត្រូវតាមនីតិវិធីឡើយ ហើយអាចជាការតម្រូវចិត្តប្រទេសវៀតណាម ។ ពីព្រោះកន្លងមកព្រះអង្គធ្លាប់បានទាក់ទងជាមួយសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលចលនានេះកំពុងទាមទារសិទ្ធិសេរីភាពពីវៀតណាម ។ សង្ឃប្រកាសរបស់សម្តេចសង្ឃទេព វង្ស ឱ្យចាប់ខ្លួនព្រះចៅអធិការទឹម សាខននោះ ត្រូវបានបកប្រែជាភាសាវៀតណាម រួចធ្វើឱ្យអាជ្ញាធរវៀតណាមផ្សព្វផ្សាយនៅខេត្តមាត់ជ្រូក ។

-អាចជាការគំរាមកំហែងបំភិតបំភ័យដល់ព្រះសង្ឃខ្មែរក្រោម ឱ្យលែងហ៊ានសកម្មភាពទាមទារសិទ្ធិសេរីភាព និងទប់ស្កាត់កុំឱ្យព្រះសង្ឃ/ប្រជាពលរដ្ឋខ្មែរក្រោមរត់ឡើងមកពឹងពាក់ស្នាក់អាស្រ័យវត្តនេះទៀត ។

-ចំណែកបញ្ហាស្រីញីវិញនោះ គឺជាការរៀបចំពីអាជ្ញាធរ ឬក៏មន្ត្រីសង្ឃជាន់ខ្ពស់ណាមួយដើម្បីដាក់បន្ទុកទៅលើព្រះសង្ឃ និងធ្វើឱ្យប្រជាពលរដ្ឋយល់ច្រឡំ ស្អប់ព្រះអង្គ។ ពីព្រោះស្ត្រីរូបនេះត្រូវបានគេឆែកឆេររកឃើញក្រោយពេលព្រះអង្គមិននៅក្នុងវត្ត ហើយការឆែកឆេរនោះមិនមានដីកាឆែកឆេរឡើយ ។ លុះមកដល់ថ្ងៃទី១-៧-២០០៧ ទើបមានដីកាឆែកឆេរពីព្រះរាជអាជ្ញា ហើយរៀបចំធ្វើដើម្បីផ្សព្វផ្សាយឡើងវិញម្តងទៀត ។

-ព្រះចៅអធិការអង្គនេះប្រហែលជាត្រូវបានគេបញ្ជូនទៅវៀតណាមពិតប្រាកដ ពីព្រោះគេចង់ឱ្យជាដង្វាយ (កាដូ)ទៅវៀតណាម ។ ឱ្យវៀតណាមធ្វើទុក្ខបុកម្និញឱ្យអស់ពីចិត្ត ដើម្បីគំរាមព្រះសង្ឃ និងពលរដ្ឋ

ខ្មែរកម្ពុជាក្រោម មើលឃើញថា បើប្រឆាំងវៀតណាមទៀតគឺត្រូវតែស្លាប់, មិនអាចជ្រកកោណប្រទេសកម្ពុជាបានឡើយ។ ប៉ុន្តែដែលថាព្រះអង្គស្ម័គ្រចិត្តឱ្យផ្សឹក និងបញ្ជូនទៅវៀតណាមនោះ គឺជារឿងមួលបង្កាច់ទាំងស្រុង មិនអាចទទួលបានឡើយ។

**វិធានការដោះស្រាយដោយ KKKHRO និងក្រុមសិទ្ធិមនុស្សផ្សេងទៀត**

-ថ្ងៃទី៣០-៦-២០០៧ ដដែលនោះ KKKHRO ប្រចាំខេត្តតាកែវបានទៅឃ្លាំមើលករណីនេះដល់ទីកន្លែង។

-ថ្ងៃទី០១និង ទី០២-៧-២០០៧ KKKHRO ប្រចាំខេត្តតាកែវបានទៅសំភាសន៍គ្រួសារជនរងគ្រោះ និងសាក្សីផ្សេងទៀត។

-ថ្ងៃទី-១-៧-២០០៧ KKKHRO និងគណៈកម្មាធិការសំរបសំរួលខ្មែរកម្ពុជាក្រោម មានទាំងព្រះសង្ឃផងបានចុះទៅដល់វត្តភ្នំដិន និងវត្តព្រះមេគណខេត្ត សីហារតនារាម ដើម្បីប្រមូលព័តិមានបន្ថែម។

-ថ្ងៃទី០២ និងទី០៣ ខែ៧ ឆ្នាំ២០០៧ KKKHRO ភ្នំពេញ និងគណៈកម្មាធិការប្រព្រិត្តិកម្មព្រមទាំង UNCOHCHR បានចុះស៊ើបអង្កេតដល់ទីកន្លែង : ទៅវត្តភ្នំដិន, ភូមិតាឡឹង, ជួបព្រះមេគណ,ព្រះរាជអាជ្ញា និងអធិការរងប៉ូលិសខេត្តតាកែវ។

-ថ្ងៃទី ០៤-៧-២០០៧ KKKHRO និងគណៈកម្មាធិការប្រព្រឹត្តិកម្មការពារសិទ្ធិមនុស្ស បានចេញសេចថ្លែងការណ៍ថ្កោលទោសអំពីការចាប់ផ្សឹកព្រះអង្គ។

**វិធានការខាងមុខ :**

-ទទួលសិទ្ធិពីគ្រួសារព្រះសង្ឃរងគ្រោះធ្វើជាដើមបណ្តឹង ប្តឹងពីករណីបាត់ខ្លួនព្រះអង្គ , ពីបទក្រុមជនមិនស្គាល់មុខចាប់ពង្រត់ព្រះអង្គ, ទាមទារសំណងជំងឺចិត្ត និងរកមេធាវីជួយការពាររឿងក្តីនេះផង។

**លទ្ធផលអន្តរាគមន៍**

(តាមដានបន្ត)